ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៥
ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១
សាលដីកា
លេខ: ០៤ I
ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២

# សាលដីកា
## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៨៣ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] **ឃឿន** ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០ ក្រVI.ភស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

-**ជនជាប់ចោទ (ប្តឹងសាទុក្ខ)** ៖ ឈ្មោះ [redacted] **ឃឿន** ហៅ **ខាឃុន** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ ជាងធ្វើផ្ទះ ទីកន្លែងកំណើត ភូមិអញ្ចាញ ឃុំចេកចូក ស្រុកបូរីជលសារ ខេត្តតាកែវ ទីលំនៅ



Scanned with CamScanner

មុនពេលឃុំ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted]មានកូន០៣នាក់ ជានីតិជន ទោសពីមុន គ្មាន ។

(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥០២ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៦)

-មានមេធាវីការពារសិទ្ធិៈ លោក [redacted] ចូវ៉ា

**-ត្រូវជាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ** លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបំពាក់ដាក់តាមខ្លួនកាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ[redacted] **ស៊ីណាត** ភេទស្រី អាយុ៣៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិជំនាប់ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ២០ និង ២៥នាទី ស្ថិតនៅចំណុចខាងជើងផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានករណី លួចមានស្ថានទម្ងន់ដោយសារមរណៈភាពជនរងគ្រោះ និងបំពាក់ដាក់តាមខ្លួនកាន់កាប់ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] សំអុល ,ឈ្មោះ[redacted] វុទ្ធី និងឈ្មោះ [redacted] យឿង ដែលបានធ្វើសកម្មភាពប្រើប្រាស់អាវុធម៉ាក AK ជាមធ្យោបាយបណ្តាលឱ្យជនរងគ្រោះ[redacted]ជឿន ជាម្ចាស់ផ្ទះបានបាត់បង់ជីវិត ។ ក្រោយពេលធ្វើសកម្មភាពជនត្រូវចោទទាំងបីខាងលើបានរត់គេចខ្លួនបាត់ ។ ចំពោះឈ្មោះ[redacted]ម៉ុន្នា បានធ្វើសកម្មភាពលក់អាវុធម៉ាក AK ទៅឱ្យឈ្មោះ [redacted] សំអុល ហើយជននេះក៏បានយកទៅលក់ឱ្យឈ្មោះ[redacted]វី និងឈ្មោះ [redacted] វ៉ែន បន្តទៀតដោយឡែកឈ្មោះ ឌី និងឈ្មោះ វ៉ាន់ ក៏មានជាប់ពាក់ព័ន្ធជាមួយនិងឈ្មោះ[redacted]សំអុល ក្នុងការចែកចាយអាវុធដោយគ្មានការអនុញ្ញាតផងដែរ ។ មុននឹងធ្វើសកម្មភាពឈ្មោះ[redacted] ស្រីសួគ៌ ជាប្រពន្ធរបស់ឈ្មោះ[redacted] សំអុល បានទិញម្ហូបអាហាររៀបចំបាយទឹក ហើយថែមទាំងជូនឈ្មោះ[redacted]សំអុល ដោយជិះម៉ូតូទៅ ហើយក៏បានត្រឡប់មកវិញផងដែរ ។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ២៥៩ "ខ" ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖



Scanned with CamScanner

១-ឱ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ស្រីស្អត់ ភេទស្រី អាយុ២២ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ , ៣៥៣ ,៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

២-ឱ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ម៉ុន្នា ភេទប្រុស អាយុ៤៨ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ពីបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ ដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៣-ផ្តន្ទាទោសលើជនជាប់ចោទ ៖

ក-ឈ្មោះ [redacted] វុទ្ធី ហៅ ធី ភេទប្រុស អាយុ ៣៧ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ។

ខ-ឈ្មោះ [redacted] យឿង ហៅ អាយួន ភេទប្រុស អាយុ ៣៥ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ។

ម្នាក់ៗដាក់ពន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៦០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ ៣២ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគាររយៈពេល ២៥ឆ្នាំ ពីបទលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបំពាក់ដាក់តាមខ្លួនកាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃតម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទា



Scanned with CamScanner

ទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៥-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted] វុទ្ធី ហៅ ធី ភេទប្រុស អាយុ ៣៧ឆ្នាំ ,ឈ្មោះ[redacted]យឿង ហៅ អាយួន ភេទប្រុស អាយុ ៣៥ឆ្នាំ និងឈ្មោះ[redacted] សំអុល ហៅ [redacted]សំអុល ភេទប្រុស អាយុ ៣២ឆ្នាំ សងសំណងជំងឺចិត្តចំនួន ៣០.០០០.០០០ (សាមសិបលាន)រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសាលក្រមចូលជាស្ថាពរ ។

៦-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ[redacted] សំអុល ហៅ [redacted]សំអុល ភេទប្រុស អាយុ ៣២ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ។

៧-វត្ថុតាងដែលមានក្នុងកំណត់ទទួលវត្ថុតាងរួចមាន ៖

-កាំភ្លើងអាកា(AK) ចំនួន ៤ដើម ស្ទាយបត់ចំនួន ០១ដើម មានលេខតួ ១៦២៣៤៣ និងស្ទាយកាត់ ៣ដើម មានលេខតួ ៥៣១៩៩៥៤ ,លេខតួ ៥៣១៨៨៤១ ,លេខតួ ៥៣២១៥៥២ ,បង់ចំនួន ០៤បង់ ,គ្រាប់ចំនួន ៨៦គ្រាប់ ស្នាប់ដៃចំនួន ០២ ,ស្ទាយដោះចេញចំនួន ០២ ,គល់អុសចំនួន ០២កំណាត់ ,ធុងប៉េត្រូចំនួន ០១ ពណ៌ស ស័ង្កសីមួយផ្ទាំង, ពិល ០១ពណ៌ក្រហម, ដង្កាប់០១, ក្តារកំបោរ ២ជ័រពណ៌ខៀវ, ស្លាបព្រាដែករៀបឥដ្ឋ ០១, កន្ត្រៃដែក០១, ដងកន្ត្រៃកាត់ដែក ០២, ម៉ែត្ររមូល ០១ ខូចពណ៌ខៀវ, អាវប៉ាក់ដៃវែង ០២, ខោប៉ាក់ជើងវែង០១, ខ្សែកាំភ្លើង០២, ស្បែកជើងផ្ទាត់ ០៣គូ, ស្បែកជើងប៉ាត់តា ០១គូ ក្រណាត់ខោជើងវែង ០២, អាវយឺតដៃខ្លីពណ៌ក្រហម ០១, មួកយឺតពណ៌ខ្មៅក្រៅក្រហមក្នុង០១, ខោលីអូពណ៌ខៀវ ០១, អាវដៃវែងឆ្នូតពណ៌សលាយទឹកប៊ិច០១, ក្រណាត់កៅស៊ូពណ៌ស ០១ផ្ទាំង, ថង់កាតពណ៌ស ០៣ ពណ៌លឿង ០១, ថង់ប្លាស្ទិចពណ៌ស ០១ ពណ៌លឿង ០១, សំបកគ្រាប់ធុន ៧៦២មម x ៣៩មម ចំនួន ០៣ សំបក មានលេខសំគាល់គូថ ២៧០ ពណ៌ទង់ដែងដូចគ្នា និងដង្កាប់ដែក ០១ ដងស្រោមជ័រពណ៌លឿងលាយខ្មៅ (ដង្កាប់ ថ្មី) សម្រេចរឹបអូសទុកជាសម្បត្តិ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] វុទ្ធី ហៅ ធី, ឈ្មោះ[redacted] យឿង ហៅ អាយួន, ឈ្មោះ [redacted]ស្រីសួគ៌, ឈ្មោះ [redacted] ម៉ុន្ថា កំបាំងមុខជនជាប់ចោទឈ្មោះ[redacted] សំអុល ហៅ[redacted] សំអុល និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៧៨ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ[redacted] **យឿង** និងឈ្មោះ[redacted] **វុទ្ធី** គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។



Scanned with CamScanner

**-បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ១០ ក្រVI.ក.ស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៨ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted]យឿង និងឈ្មោះ[redacted]វុទ្ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៥៩ "ខ" ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]យឿង និងឈ្មោះ[redacted] វុទ្ធី តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]យឿង និងឈ្មោះ[redacted] វុទ្ធី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា ៖ យោងតាមឯកសារទាំងអស់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌបានបង្ហាញថា ការសម្រេចសេចក្តីរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញមានលក្ខណៈត្រឹមត្រូវហើយ ព្រោះការសម្រេចផ្អែកលើសំអាងហេតុដែលស្របតាមអង្គហេតុ និងអង្គច្បាប់ ដូចមានបញ្ជាក់នៅក្នុងសាលដីកាស្រាប់ ។ កំណត់ហេតុរបស់សមត្ថកិច្ចនគរបាលបញ្ជាក់ថា ជនជាប់ចោទបានប្រព្រឹត្តបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

ហេតុដូច្នេះ យល់ឃើញថា គប្បីតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

<u>តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានសុំ ៖</u>

១-ទទួលបណ្តឹងសាទុក្ខលេខ ៨៣ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]យឿង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០ ក្រ.VI.ភ.ស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

+លោកមេធាវី [redacted] បូរ៉ា ការពារជនជាប់ចោទឈ្មោះ [redacted] យឿង ធ្វើសេចក្តីសន្និដ្ឋានថា ក្នុងរឿងនេះខ្ញុំបាទបានដាក់សេចក្តីសន្និដ្ឋានជូនតុលាការកំពូលរួចហើយ កូនក្តីខ្ញុំប្តឹងសាទុក្ខមកនេះ គឺគាត់សូមបន្ធូបន្ថយទោស ។ ថ្ងៃកើតហេតុពេលយប់សាក្សីមិនបានឃើញផ្ទាល់ តាមរបាយការណ៍បូលីសមានបាញ់មែនប្លន់ធ្វើអោយជនរងគ្រោះស្លាប់មានគ្រាប់មួយធ្លាយខាងមុខ កូនក្តីខ្ញុំ [redacted] យឿង បាញ់ប្រហើរទៅលើ ពេលកើតហេតុមានគ្នាបីនាក់កូនក្តីខ្ញុំនៅក្រៅបងឈ្មោះ [redacted] វុទ្ធី នៅផ្ទាល់ ។ តុលាការជាន់ក្រោមអនុវត្តមាត្រា ៣៦០ បើអង្គហេតុខុសគ្នា គួណាតុលាការបញ្ជូនទៅសាលាឧទ្ធរណ៍វិញ ។ សំណូមពរ បញ្ជូនរឿងនេះទៅក្រោមវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៣ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យឿង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ទោះបីនាពេលសវនាការ អវត្តមានជនជាប់ចោទ ប៉ុន្តែមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានដាក់សេចក្តីសន្និដ្ឋានការពាររួចហើយ ហើយនាពេលសវនាការនេះក៏មានវត្តមានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទផងដែរ ។ ដូច្នេះផ្អែកតាមស្មារតីមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌតុលាការកំពូលអាចបន្តសវនាការនេះបាន ។

៣-យល់ឃើញថា នាពេលសវនាការមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានលើកឡើងថា ជនជាប់ចោទប្តឹងសាទុក្ខត្រឹមតែសុំបន្ធូរបន្ថយទោសប៉ុណ្ណោះ ។ តាមអង្គហេតុនៃការចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោសដោយប្រើអាវុធឃើញថា មានបាញ់បីគ្រាប់ពេលយប់ ពុំមានសាក្សីឃើញផ្ទាល់ភ្នែក ក្រោយពេលបាញ់ មន្ត្រីនគរបាលបានកំណត់ស្នាមរបួសលើជនរងគ្រោះចូលពីខាងមុខពីរគ្រាប់ ចូលពីខាងក្រោយមួយគ្រាប់ហើយជនរងគ្រោះបានស្លាប់នៅមន្ទីរពេទ្យ ។ ជនជាប់ចោទឈ្មោះ [redacted] យឿង មិនមែនជាមេក្លោងទេ ហើយក៏មិនមែនជាជនដៃដល់ដែរ ឈ្មោះ [redacted] សំអុល ជាមេខ្លោងជាអ្នកបាញ់ពីរគ្រាប់ ឈ្មោះ [redacted] វុទ្ធី ជាអ្នកបាញ់មួយគ្រាប់ ចំណែកឈ្មោះ [redacted] យឿង គ្រាន់តែបាញ់បង្អែលឡើងលើ មិនបានបាញ់សំដៅជនរងគ្រោះ



Scanned with CamScanner

ឡើយ ។ ការចោទប្រកាន់តាមមាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ ពុំត្រឹមត្រូវទេ គប្បីអនុវត្តតាមមាត្រា ៣៥៧ ឬមាត្រា ៣៥៨ នៃក្រមព្រហ្មទណ្ឌ ដែលអាចដាក់ទណ្ឌកម្មជនជាប់ចោទកំរិតពី១០ឆ្នាំ រួមទាំងបទប្រើអាវុធដោយគ្មានច្បាប់អនុញ្ញាតផង ។ ដូច្នេះបើតុលាការកំពូលរកឃើញថា ជនជាប់ចោទប្រព្រឹត្តបទផ្សេង សំណូមពរបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ ។ ម្យ៉ាងវិញទៀតតុលាការក៏អាចពិចារណាអំពីស្ថានសម្រាលទោសដល់ជនជាប់ចោទតាមបទបញ្ញត្តិនេះ ដោយគិតគូរពីការសារភាពទទួលស្គាល់ថាជនជាប់ចោទបានបាញ់បង្អើល និងបានសហការជាមួយអាជ្ញាធរផងដែរ ។ មូលហេតុដែលលើកឡើងដោយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទតុលាការកំពូលយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទពុំមានភាពច្បាស់លាស់ទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយអំពើរបស់ជនជាប់ចោទរួមជាមួយចារីដទៃទៀតបណ្តាលឲ្យជនរងគ្រោះស្លាប់ប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ត្រូវផ្តន្ទាទោសពីបទ អំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ តាមមាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ ដែលអាចឲ្យតុលាការព្រហ្មទណ្ឌពិចារណាកម្រិតទោសដាក់ពន្ធនាគារកំណត់ពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ។ ការដែលតុលាការអង្គសេចក្តីសម្រេចសេចក្តីផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារកំណត់រយៈពេល ២០(ម្ភៃ)ឆ្នាំ ត្រឹមត្រូវតាមបទបញ្ញត្តិនេះ ដោយពុំចាំបាច់ពិចារណាលើស្ថានសម្រាលដល់ជនជាប់ចោទបន្ថែមទៀតទេ ។ ដូច្នេះ មូលហេតុដែលលើកឡើងដោយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទពុំចូលត្រង់ចំណុចណាមួយនៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដែលគប្បីសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] យឿង ទាំងស្រុង ។

៤-យល់ឃើញថា នាពេលសវនាការតំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ថា ជនជាប់ចោទមិនបានដាក់សារណាការពារមកតុលាការកំពូលទេ ដែលតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឃើញថា មិនមានបញ្ហាច្បាប់ដែលអាចឲ្យតុលាការកំពូលលើកយកមកពិចារណាទេ ។ ម្យ៉ាងទៀត សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញមានសំអាងហេតុសព្វគ្រប់ សំណូមពរតុលាការសម្រេចសេចក្តីតាមច្បាប់ ។ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលស្របតាមសំអាងហេតុខាងលើហើយ ក្រុមប្រឹក្សាពុំចាំបាច់លើកយកមកពិចាណាឡើងវិញទេ ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០ ក្រ.VI ក.ស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចសេចក្តីត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ៨៣ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យឿង ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០ ក្រ .VI ក.ស ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២២ ។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

.............................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner